**សូមឈប់ និងពិនិត្យម្តងទៀត ថាតើនេះជាព័ត៌មានត្រឹមត្រូវសម្រាប់អ្នកដែរឬទេ!** KHMER

សន្លឹកព័ត៌មាននេះសម្រាប់អ្នកបោះឆ្នោតនៅក្នុងតំបន់ទាំងអស់នៃរដ្ឋកាលីហ្វូញ៉ា **លើកលែងតែ** តំបន់ Amador, Butte, Calaveras, El Dorado, Fresno, Los Angeles, Madera, Mariposa, Napa, Nevada, Orange, Sacramento, San Mateo, Santa Clara និងតំបន់ Tuolumne ។

# ស្គាល់សិទ្ធិបោះឆ្នោតរបស់អ្នក

ASIAN AMERICANS ADVANCING JUSTICE
ASIAN LAW CAUCUS

## ត្រៀមខ្លួនដើម្បីបោះឆ្នោត

ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតណាមួយ ជាដំបូងអ្នកត្រូវចុះឈ្មោះដើម្បីបោះឆ្នោតជាមុនសិន! អ្នកអាចចុះឈ្មោះបោះឆ្នោតបាន ប្រសិនបើអ្នកជា៖

- ពលរដ្ឋអាមេរិក
- អ្នកស្រុកនៃរដ្ឋកាលីហ្វ៊ីញ៉ា
- នឹងមានអាយុ ១៨ ឆ្នាំ ឬច្រើនជាងនេះនៅថ្ងៃបោះឆ្នោត
- បច្ចុប្បន្នមិនជាប់ពន្ធនាគារ ឬស្ថិតក្រោមការដោះលែងជាបណ្តោះអាសន្នក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ និង
- មិនត្រូវបានរកឃើញដោយតុលាការថា “ខ្វះសមត្ថភាពផ្នែកស្មារតី។”

### ចុះឈ្មោះរួចហើយ?

ពិនិត្យ និងបញ្ជាក់ព័ត៌មានស្តីពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក។ ប្រើ voterstatus.sos.ca.gov ដើម្បី៖

- បញ្ជាក់អាសយដ្ឋានផ្ញើសាររបស់អ្នក
- បន្ថែម ឬបញ្ជាក់អាសយដ្ឋានអ៊ីម៉ែលណាមួយ ដើម្បីទទួលបានព័ត៌មានឱ្យទាន់ពេលវេលាពីការិយាល័យបោះឆ្នោតតំបន់របស់អ្នក
- បង្ហាញភាសាជាចំណង់ចំណូលចិត្តរបស់អ្នក ដើម្បីទទួលបានឯកសារដែលបកប្រែរួច ប្រសិនបើមាននៅក្នុងតំបន់របស់អ្នក។

### ចង់ចុះឈ្មោះ?

ដល់ថ្ងៃច័ន្ទ ទី 19 ខែតុលា អ្នកអាចចុះឈ្មោះ៖

- តាមអ៊ីធើណិត តាមរយៈ: registertovote.ca.gov
- នៅ DMV, ការិយាល័យប៉ុស្តិ៍, បណ្ណាល័យ ឬការិយាល័យបោះឆ្នោតរបស់អ្នក ឬ
- តាមរយៈការហៅទូរស័ព្ទ (800) 345-8683 ដើម្បីស្នើសុំពាក្យសុំចុះឈ្មោះបោះឆ្នោត ដែលត្រូវតែផ្ញើទៅប្រៃសណីយ៍ ត្រឹមថ្ងៃទី ១៩ ខែតុលា។ មិនត្រូវការត្រាទេ!

### ចុះបើខ្ញុំត្រូវការចុះឈ្មោះក្រោយថ្ងៃទី19 ខែតុលា?

គ្មានបញ្ហា! អ្នកនៅតែអាចប្រើ “ការចុះឈ្មោះរបស់អ្នកបោះឆ្នោតនៅថ្ងៃតែមួយ” ដើម្បីចុះឈ្មោះ និងបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត។

ជម្រើស ១៖ ទៅដោយផ្ទាល់ដើម្បីចុះឈ្មោះ និងបោះឆ្នោតនៅថ្ងៃតែមួយ។

| | |
|---|---|
| ថ្ងៃទី19 ខែតុលា - ថ្ងៃទី 2 ខែវិច្ឆិកា | ទៅកាន់ការិយាល័យបោះឆ្នោតតំបន់របស់អ្នកដើម្បីចុះឈ្មោះ និងបោះឆ្នោត។<br>ស្វែងរកការិយាល័យបោះឆ្នោតរបស់អ្នកនៅទីនេះ៖ sos.ca.gov/county-elections-offices |
| ថ្ងៃទី 3 ខែវិច្ឆិកា (ថ្ងៃបោះឆ្នោត) | ទៅកាន់កន្លែងបោះឆ្នោតណាមួយនៅក្នុងតំបន់របស់អ្នកដើម្បីចុះឈ្មោះ និងបោះឆ្នោត។ ប្រសិនបើអ្នកចង់បោះឆ្នោតលើការប្រកួតប្រជែងតាមមូលដ្ឋានទាំងអស់ សូមទៅកាន់កន្លែងបោះឆ្នោតណាមួយ ដែលនៅជិតផ្ទះរបស់លោកអ្នក។ សូមបញ្ចូលអាសយដ្ឋានរបស់អ្នកនៅទីនេះ ដើម្បីស្វែងរកកន្លែងបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក៖ sos.ca.gov/elections/polling-place.<br>អ្នកក៏អាចហៅទូរស័ព្ទទៅការិយាល័យបោះឆ្នោតតំបន់របស់អ្នក ដើម្បីស្វែងរកកន្លែងដែលត្រូវទៅ។ ស្វែងរកលេខទូរស័ព្ទការិយាល័យបោះឆ្នោតរបស់អ្នកនៅទីនេះ៖ sos.ca.gov/county-elections-offices. |

ជម្រើស ២៖ ប្រសិនបើអ្នកមិនត្រូវបានចុះឈ្មោះបោះឆ្នោត និងមិនអាចទៅទីតាំងបោះឆ្នោតបាន សូមទំនាក់ទំនងការិយាល័យបោះឆ្នោតតំបន់របស់អ្នក ដើម្បីសួរអំពីរបៀបដែលអ្នកអាចចុះឈ្មោះ និងបោះឆ្នោតពីចម្ងាយ ដោយប្រើ “ការបោះឆ្នោតដែលអាចប្រើបានពីចម្ងាយតាមរយៈប្រៃសណីយ៍ ។”

### ការបោះឆ្នោតទូទៅឆ្នាំ 2020 របស់រដ្ឋកាលីហ្វូញ៉ា

| | |
|---|---|
| ចាប់ពីថ្ងៃទី 5 ខែតុលា ឆ្នាំ 2020 | សន្លឹកឆ្នោតដែលបានផ្ញើទៅអ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះរួច៖ |
| ថ្ងៃអង្គារ ទី 6 ខែតុលា ឆ្នាំ 2020 | ប្រអប់ដាក់សន្លឹកឆ្នោតបើក៖ |
| ថ្ងៃច័ន្ទ ទី 19 ខែតុលា ឆ្នាំ 2020 | កាលផុតកំណត់នៃការចុះឈ្មោះ |
| ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020 (ថ្ងៃបោះឆ្នោត) | ថ្ងៃចុងក្រោយដើម្បីបោះឆ្នោត៖<br>តំបន់ភាគច្រើននឹងមានការបោះឆ្នោតមុនពេលកំណត់ ចាប់ផ្តើមពីថ្ងៃទី 31 ខែតុលា ឆ្នាំ 2020។ |

# បោះឆ្នោតដោយរបៀបណា? អ្នកមានជម្រើសជាច្រើន!

## បោះឆ្នោតពីផ្ទះ

ប្រសិនបើអ្នកចុះឈ្មោះត្រឹមថ្ងៃទី 19 ខែតុលា អ្នកនឹងទទួលបានដោយស្វ័យប្រវត្តិនូវសន្លឹកឆ្នោតនៅក្នុងប្រៃសណីយ៍ ដោយមានសេចក្តីណែនាំអំពីរបៀបក្នុងការបំពេញ និងបញ្ជូនសន្លឹកឆ្នោតមកវិញ។ អ្នកអាច៖

- សូមផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍ -- មិនត្រូវការត្រាទេ!
    - ចូរចងចាំថាត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទលើប្រអប់សំបុត្រសន្លឹកឆ្នោតរបស់អ្នក។
    - ត្រូវប្រាកដថាសន្លឹកឆ្នោតរបស់អ្នកមានត្រានៅថ្ងៃ ឬមុនថ្ងៃបោះឆ្នោត។ ឬមុនថ្ងៃបោះឆ្នោត។
- សូមដាក់សន្លឹកឆ្នោតនៅកន្លែងបោះឆ្នោតណាមួយនៅក្នុងតំបន់របស់អ្នក។
    - អ្នកអាចស្វែងរកកន្លែងបោះឆ្នោតនៅលើវិបសាយការិយាល័យបោះឆ្នោតតំបន់របស់អ្នក ឬពិនិត្យ sos.ca.gov/elections/polling-place សម្រាប់កន្លែងបោះឆ្នោតនៅជិតអាសយដ្ឋានរបស់អ្នក។
    - ប្រហែលជាមាន “ប្រអប់ដាក់សំបុត្រ” ដែលមានសុវត្ថិភាព នៅកន្លែងដែលអ្នកអាចដាក់សន្លឹកឆ្នោតរបស់អ្នក រយៈពេលច្រើនសប្តាហ៍រហូតដល់ថ្ងៃបោះឆ្នោត។

## បោះឆ្នោតដោយផ្ទាល់

ប្រសិនបើអ្នកចង់បោះឆ្នោតដោយផ្ទាល់ អ្នកអាច! ដើម្បីធ្វើឱ្យដំណើរការកាន់តែងាយស្រួល សូមសាកល្បងយកសន្លឹកឆ្នោតរបស់អ្នកទៅជាមួយអ្នក ដើម្បីដាក់ ប្រសិនបើអ្នកទទួលបានសន្លឹកឆ្នោតមួយតាមរយៈប្រៃសណីយ៍។

ថ្ងៃបោះឆ្នោតនៅ **ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020**។ ការបោះឆ្នោតនឹងបើកចាប់ពីម៉ោង **7 ព្រឹក ដល់ម៉ោង 8 យប់**។ ដរាបណាអ្នកស្ថិតនៅក្នុងជួរមុនម៉ោង 8 យប់ អ្នកនឹងអាចបោះឆ្នោតរបស់អ្នកបាន។

**តំបន់ភាគច្រើននឹងផ្តល់ជូននូវការបោះឆ្នោតដោយផ្ទាល់ ចាប់ពីថ្ងៃសៅរ៍ ទី 31 ខែតុលា ឆ្នាំ 2020**។ សូមពិនិត្យជាមួយមន្ត្រីបោះឆ្នោតនៅតាមមូលដ្ឋានរបស់អ្នក។

ដើរចូលទៅកាន់កន្លែងបោះឆ្នោតរបស់អ្នក ស្វែងរកតុចម្បង រួចហើយផ្តល់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដល់អ្នកធ្វើការ។ ប្រសិនបើអ្នកចង់បោះឆ្នោតជាភាសាណាមួយ ក្រៅពីភាសាអង់គ្លេស សូមសួរថាតើពួកគេមានឯកសារណាមួយជាភាសានោះដែរឬទេ ហើយថាតើអ្នកធ្វើការនៅកន្លែងបោះឆ្នោតនិយាយភាសានោះដែរឬទេ។

### តើខ្ញុំទៅបោះឆ្នោតនៅកន្លែងណា?

កន្លែងបោះឆ្នោតដែលត្រូវបានចាត់តាំងរបស់អ្នកអាចរកឃើញនៅលើឯកសារ ដែលអ្នកទទួលបានពីការិយាល័យបោះឆ្នោតតំបន់របស់អ្នកមុនការបោះឆ្នោត។ អ្នកអាចរកមើលនៅទីនេះ៖ sos.ca.gov/elections/polling-place.

### តើនឹងមានកិច្ចការពារសុខភាពសាធារណៈដែរឬទេ?

មាន។ បុគ្គលិកកន្លែងបោះឆ្នោតនឹងពាក់ម៉ាស់ និងធ្វើតាមគោលការណ៍ណែនាំស្តីពីសុខភាពសាធារណៈ និងបង្កើតកន្លែងបោះឆ្នោត ដើម្បីអនុញ្ញាតឱ្យមានការនៅដាច់ឆ្ងាយពីគ្នា។ អ្នកបោះឆ្នោតត្រូវតែអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីសុខភាពសាធារណៈរបស់រដ្ឋ និងថ្នាក់មូលដ្ឋាន រួមមានការពាក់របាំងមុខ និងការរក្សាគម្លាតរាងកាយ។

### តើខ្ញុំអាចនាំនរណាម្នាក់ទៅជួយខ្ញុំបោះឆ្នោតបានទេ?

បាន។ ច្បាប់រដ្ឋកាលីហ្វូញ៉ាអនុញ្ញាតឱ្យអ្នកនាំមនុស្សបានពីរនាក់ដើម្បីជួយបោះឆ្នោតដោយផ្ទាល់ ដរាបណាពួកគេមិនតំណាងនិយោជករបស់អ្នក ឬសហជីពរបស់អ្នក។ សូមនាំសមាជិកគ្រួសារ ឬមិត្តភក្តិ។

### តើខ្ញុំចាំបាច់ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណរបស់ខ្ញុំនៅពេលបោះឆ្នោតដែរឬទេ?

ស្ទើរតែគ្រប់ស្ថានភាពទាំងអស់ មិនចាំបាច់ទេ។ អ្នកគ្រាន់តែបង្ហាញឯកសារ ប្រសិនបើអ្នកបោះឆ្នោតជាលើកទីមួយ និងប្រសិនបើអ្នកមិនបានបញ្ចូលលេខអាជ្ញាប័ណ្ណបើកបរ លេខអត្តសញ្ញាណប័ណ្ណរដ្ឋ ឬលេខសន្តិសុខសង្គម (លេខសូសាល់) នៅពេលដែលអ្នកចុះឈ្មោះបោះឆ្នោត។ ប្រសិនបើមានករណីបែបនេះ ឯកសារច្រើនអាចប្រើការបាន។ សូមហៅទូរសព្ទទៅកាន់មន្ត្រីបោះឆ្នោតរបស់អ្នកជាមុន ប្រសិនបើអ្នកមានក្តីបារម្ភ។

### ចុះបើខ្ញុំមានបញ្ហានៅពេលកំពុងបោះឆ្នោត?

សូមកុំបោះបង់! សូមស្នើសុំប្រើការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយ ដើម្បីចុះឈ្មោះឡើងវិញ និងបោះឆ្នោត។ ប្រសិនបើអ្នកមិនអាចធ្វើបែបហ្នឹងបាន ដោយសារហេតុផលណាមួយ សូមស្នើសុំសន្លឹកឆ្នោតបណ្តោះអាសន្ន ជាសន្លឹកឆ្នោតដែលនឹងត្រូវបានរាប់ក្រោយថ្ងៃបោះឆ្នោត ប្រសិនបើមន្ត្រីបោះឆ្នោតបញ្ជាក់លក្ខខណ្ឌគ្រប់គ្រាន់របស់អ្នក។

ឬ ហៅទូរសព្ទទៅកាន់លេខទាន់ហេតុការណ៍នៃកិច្ចការពារអ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោត មួយក្នុងចំណោមលេខទាំងនោះ៖

- 866-687-8683 សម្រាប់ជំនួយជាភាសាអង់គ្លេស។
- 888-274-8683 សម្រាប់ជាភាសាអង់គ្លេស, ចិន, ចិនកាតាំង, វៀតណាម, កូរ៉េ, បង់ហ្គា, អ៊ឺឌូ, ហិណ្ឌូ និង តាហ្គាឡុក ។
- 888-839-8682 សម្រាប់ជំនួយជាភាសាអង់គ្លេស និងអេស្ប៉ាញ ដោយមិនគិតថ្លៃ។

## តើខ្ញុំនឹងអាចបោះឆ្នោតជាភាសាណាមួយក្រៅពីភាសាអង់គ្លេសបានទេ?

ជំនួយផ្នែកភាសាខុសគ្នាទៅតាមតំបន់។ ប្រសិនបើអ្នកបោះឆ្នោតតាមប្រៃសណីយ៍ សូមហៅទូរសព្ទទៅកាន់មន្ត្រីការិយាល័យបោះឆ្នោតតំបន់របស់អ្នក ដើម្បីស្វែងរកអ្វីដែលមាននៅក្នុងភាសាដែលអ្នកចង់បាន នៅក្នុងតំបន់របស់អ្នក។ ប្រសិនបើអ្នកបោះឆ្នោតនៅកន្លែងបោះឆ្នោត សូមសួរថាតើមានឯកសារដែលបកប្រែរួចហើយដែរឬទេ និងថាតើបុគ្គលិកដែលវត្តមាន និយាយភាសាដែលអ្នកចង់បានដែរឬទេ។ អ្នកក៏អាចស្វែងរកមើលសញ្ញាជាភាសារបស់អ្នកផងដែរ។

ភាសាដែលអាចផ្តល់ជូននៅក្នុងតំបន់របស់អ្នក រួមមាន៖ អារ៉ាប់, អាមេនី, បង់ក្លា, ភូមា, ចិន, ហ្វាស៊ី, ហ្គូចារ៉ាទី, ហិណ្ឌូ, ម៉ុង, អ៊ីឡូកាណូ, ឥណ្ឌូនេស៊ី, ជប៉ុន, ខ្មែរ, កូរ៉េ, ឡាវ, មៀន, ម៉ុងហ្គោលី, នេប៉ាល់, ប៉ុនចា, អេស្ប៉ាញ, ស៊ីរី, តាហ្គាឡុក, តាមីល, តេលូហ្គូ, ថៃ, អ៊ុឌូ និងវៀតណាម។

អ្នកអាចស្វែងរកឯកសារចែកជូនស្តីពីភាសាដែលអាចប្រើបាននៅក្នុងការបោះឆ្នោត ដែលពន្យល់អំពីភាសាអ្វីខ្លះនៅក្នុងតំបន់របស់អ្នក៖ [advancingjustice-alc.org/know-your-voting-rights.](advancingjustice-alc.org/know-your-voting-rights)


55 Columbus Avenue, San Francisco, CA 94111 | T (415) 896-1701 | www.advancingjustice-alc.org